និង អភិវឌ្ឍន៍ និង បណ្ដាសាម៉ីជន ដែលមានការពាក់ព័ន្ធ មានភារកិច្ចអនុវត្តតាមសេចក្ដីសំរេចនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**នាយករដ្ឋមន្ត្រីទី ១**
**ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**
ព្រះហស្តលេខា និង ត្រា

**នរោត្តម រណឫទ្ធិ**

* * * *

ធ្វើនៅភ្នំពេញ , ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៤

# សេចក្ដីសំរេច លេខ ០២ ក.អ.ក
## ស្ដីពីការបង្កើតគណៈកម្មាធិការជាតិវិនិយោគ

* * *

## ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាល លេខ ១៥ អ.ន.ក្រ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្ដីពីការបង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងតាមតម្រូវការចាំបាច់ នៃការងារវិនិយោគឯកជន នៅព្រះរាជាណាចក្រកម្ពុជា

**សំរេច**

**ប្រការ ១ :** បង្កើត " គណៈកម្មាធិការជាតិវិនិយោគ " ហៅកាត់ថា " គជវ " សំរាប់ជាយន្តការជំនួយការ អចិន្ត្រៃយ៍របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហៅកាត់ " ក.អ.ក " ។ " គជវ " មាន ទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី ហើយមានសមាសភាពដូចតទៅ :

- អគ្គលេខាធិការមួយរូប ជាអ្នកគ្រប់គ្រងការងារទូទៅរបស់ " គជវ "
- អ្នកច្បាប់មួយរូប ជាសមាជិក និង ទទួលបន្ទុកផ្នែកនីតិកម្ម
- អ្នកជំនាញទេសខាងកម្មវិធីវិនិយោគមួយរូប ជាសមាជិក និង ទទួលបន្ទុកផ្នែកកម្មវិនិយោគ
- អ្នកជំនាញទេសខាងវិភាគគំរោងមួយរូប ជាសមាជិក និងទទួលបន្ទុកផ្នែកវិភាគគំរោងវិនិយោគ
- អ្នកជំនាញទេសខាងបរិដ្ឋានមួយរូប ជាសមាជិក និង ទទួលបន្ទុកផ្នែកបរិដ្ឋាន
- អ្នកជំនាញទេសខាងគ្រប់គ្រងកិច្ចសន្យាមួយរូប ជាសមាជិក និង ទទួលបន្ទុកផ្នែកត្រួតពិនិត្យ ។

អគ្គលេខាធិការ ត្រូវទទួលបន្ទុកបន្ថែមផ្នែករដ្ឋបាល ដោយផ្ទាល់ ។

**ប្រការ ២ :** " គជវ " មានភារកិច្ចដូចតទៅ :

១- លើកគំរោង និង ផ្តល់យោបល់ជូន " ក.អ.ក " ស្តីពីការរៀបចំកែលំអឯកសារច្បាប់ និង បទបញ្ញត្តិផ្សេង ៗ ដែលទាក់ទិនទៅនឹងការងារវិនិយោគ អោយកាន់តែមានសុក្រឹតភាព ដើម្បីបង្កើនប្រសិទ្ធភាពការងារក្នុងវិស័យនេះ ។ ច្បាប់ និង លិខិតបទដ្ឋានទាំងឡាយត្រូវតែបង្កលក្ខណៈអនុគ្រោះ និង លើកទឹកចិត្តដល់បណ្តាអ្នកវិនិយោគ ទាំងខាងផ្នែកពន្ធដារ ទាំងខាងផ្នែកមិនមែនពន្ធដារ ។

២- បង្គុំប្រមូលផ្តុំចងក្រងបណ្តាឯកសារច្បាប់ និង បទបញ្ញត្តិ ទាំងឡាយខាងផ្នែកវិនិយោគ សំរាប់ផ្សព្វផ្សាយដល់អ្នកវិនិយោគជាតិ និង អន្តរជាតិ ។

៣- រៀបចំរបៀបរបបធ្វើការងារតាមប្រព័ន្ធ " ច្រក ចេញ - ចូល តែមួយ " ដើម្បីសំរួលដល់កិច្ចការរបស់អ្នកវិនិយោគ ។ ក្នុងន័យនេះ :

ក- ជួយបង្កលក្ខណៈងាយស្រួល និង ផ្តល់ពត៌មានដល់អ្នកវិនិយោគអំពីវិស័យផ្សេង ៗ ដែលអាចធ្វើវិនិយោគ ហើយនិងអំពីច្បាប់វិនិយោគ និង បែបបទដែលត្រូវបំពេញ ព្រមទាំងពត៌មានចាំបាច់ផ្សេង ៗ ទៀត ។

ខ- ជួយផ្តល់មតិដល់ក្រសួង ស្ថាប័ន និង ខេត្ត ក្រុង នានា ដើម្បីសហការបានល្អជាមួយ អ្នកវិនិយោគ ។

គ- ណែនាំអោយអ្នកវិនិយោគរៀបចំឯកសារចាំបាច់ទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងគំរោង ការងារវិនិយោគនីមួយ ៗ ។

ឃ- ក្នុងករណីចាំបាច់ សំរបសំរួលការងាររវាងអ្នកវិនិយោគ និង បណ្តាក្រសួង ស្ថាប័ន និង ខេត្ត ក្រុង នានា ដើម្បីដោះស្រាយបញ្ហាផ្សេងៗ ដែលទាក់ទងនឹងការងារវិនិយោគ ។

ចាត់តាំងតំណាងអោយចូលរួមពិភាក្សា និង រៀបចំកិច្ចសន្យាវិនិយោគ ជាមួយបណ្តាក្រសួង ស្ថាប័ន និង ខេត្ត ក្រុង នានា ដែលមានការពាក់ព័ន្ធ ។

៤- រៀបចំលិខិតជូនដំណឹង និង លិខិតអនុញ្ញាតអោយវិនិយោគ តាមករណីជាក់ស្តែងនីមួយៗ ដែលបានទទួលការសំរេចហើយ ដើម្បីថ្វាយសម្តេចក្រុមព្រះ ប្រធាន " ក.អ.ក " ពិនិត្យ និងឡាយព្រះហស្តលេខា ឬ ក្នុងករណីមានការប្រទានសិទ្ធិ ដាក់ជូនអនុប្រធានពិនិត្យ និង ចុះហត្ថលេខា ហើយរៀបចំបញ្ជូនសំណុំឯកសារទាំងនោះទៅអោយសាមីជនអ្នកស្នើសុំ ។

៥- ទទួលបន្ទុកចុះបញ្ជីលក្ខន្តិកៈរបស់ក្រុមហ៊ុនវិនិយោគ នានា ។

៦- តាមដាន និង ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ និង បទបញ្ញត្តិផ្សេងទៀត ដែលទាក់ទិនទៅនឹង ការងារវិនិយោគ និង ការអនុវត្តន៍កិច្ចសន្យាវិនិយោគនានា ហើយធ្វើរបាយការណ៍ជូន " ក.អ.ក " ដើម្បីលើកវិធានការណ៍កែតម្រូវអោយបានទាន់ពេល ។

៧- សហការជាមួយអគ្គលេខាធិការ នៃ " ក.អ.ក " ដើម្បីរៀបចំកម្មវិធី និង សំណុំឯកសារសំរាប់អង្គប្រជុំរបស់ " ក.អ.ក " ដែលមានខ្លឹមសារពាក់ព័ន្ធនឹងកិច្ចការវិនិយោគឯកជន ។

៨- គ្រប់គ្រង និង ថែរក្សារាល់ឯកសាររបស់ " ក.អ.ក " ដែលទាក់ទងទៅនឹងការងារវិនិយោគឯកជន ។

៩- ធ្វើរបាយការណ៍បូកសរុបសភាពការណ៍នៃការអនុវត្តការងារវិនិយោគ ឯកជនក្នុងគ្រប់វិស័យជូន " ក.អ.ក " ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល ។

ប្រការ ៣ : ការប្រព្រឹត្តទៅនៃការងាររបស់ " គជវ " ក្នុងក្របខ័ណ្ឌយន្តការ ការងារតាមប្រព័ន្ធ " ច្រកចេញចូលតែមួយ " ត្រូវអនុវត្តដូចខាងក្រោមនេះ :

ទី ១ : អ្នកវិនិយោគត្រូវរៀបចំឯកសារចាំបាច់ទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងគំរោងវិនិយោគរបស់ខ្លួន គឺ :

- បំពេញបែបបទពាក្យសុំ ដែលមានគំរូតំកល់ទុកនៅទីតាំងរបស់ " គជវ "
- ការសិក្សា ជាបឋមអំពីសមិទ្ធលទ្ធភាព ដែលក្នុងនោះអ្នកវិនិយោគត្រូវបញ្ជាក់ ជាអាទិ៍ នូវកម្មវិធីហិរញ្ញប្បទាន អត្រាចំណេញជាសារវ័ន្ត កាលអាយុនៃការវិនិយោគ កម្រៃដែលបានពីការវិនិយោគ ព្រមទាំងការវាយតម្លៃអំពីឥទ្ធិពលលើបរិដ្ឋាន

- ឯកសារស្តីពីសកម្មភាពរបស់ក្រុមហ៊ុន

ទី ២ : បន្ទាប់ពីអ្នកវិនិយោគបានបំពេញបែបបទដូចខាងលើនេះរួចហើយ គណៈកម្មាធិការជាតិវិនិយោគត្រូវពិនិត្យសំណុំរឿងភ្លាម ហើយក្នុងករណីចាំបាច់ ត្រូវអញ្ជើញម្ចាស់ពាក្យសុំមកបំភ្លឺអំពីគំរោងវិនិយោគរបស់ខ្លួន និង អញ្ជើញអ្នកឯកទេស ឬ តំណាងក្រសួង ស្ថាប័ននិង ខេត្ត ក្រុង នានាដែលមាន ការពាក់ព័ន្ធមក ចូលរួមពិភាក្សាផ្តល់យោបល់ដើម្បីបានជាសំណុំរឿងគ្រប់គ្រាន់សំរាប់ដាក់ថ្វាយសុំការសំរេចពីសម្តេចក្រុមព្រះប្រធាន “ ក.អ.ក ” ឬ ពី “ ក.អ.ក ” ជាបន្ទាន់ តាមករណីជាក់ ស្តែងនីមួយៗឬ ដាក់ជូនអនុប្រធាន “ ក.អ.ក ”ពិនិត្យនិង សំរេចក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់ខ្លួនឬ ក្នុងក្របខ័ណ្ឌនៃការប្រទានសិទ្ធិ ។

ទី ៣ : ក្នុងការអនុវត្តន៏ការងារប្រចាំថ្ងៃ អនុប្រធាន “ ក.អ.ក ” ដោយមានការចូលរួមយោបល់ពីអគ្គលេខាធិការ នៃ “ ក.អ.ក ” និង ពីគណៈកម្មាធិការជាតិវិនិយោគ មានសិទ្ធិសំរេចតាមរបៀបរបបធ្វើការងារខាងលើនេះ លើប្រភេទសំណុំរឿងមួយចំនួនដូចមានកំណត់ខាងក្រោមនេះ :

ក- ការសុំបង្កើតក្រុមហ៊ុនវិនិយោគ ឬ សាខា ឬ បុត្រសម្ព័ន្ធ ឬ ការិយាល័យតំណាងនានា ។

ខ- ការសុំនាំចូលគ្រឿងសម្ភារៈ បរិក្ខារ វត្ថុធាតុដើម ដើម្បីអោយអ្នកវិនិយោគសំរេចគំរោងវិនិយោគរបស់ខ្លួន ដែលបានទទួលអនុម័តជាគោលការណ៏រួចហើយ ។ ការពិនិត្យ និង សំរេចនេះ ត្រូវផ្អែកលើច្បាប់វិនិយោគ ដែលមានជាធរមាន ។

គ- ការសុំគោលការណ៏លើគំរោងវិនិយោគនានា ដែលមានទំហំតូចក្រោម ( ប្រាំ ) លាន ដុល្លារអាមេរិក ។

ឃ- ការដោះស្រាយបញ្ហាទាំងឡាយ ដែលអ្នកវិនិយោគបានជួបប្រទះក្នុងការអនុវត្តសេចក្តីសំរេចរបស់ “ ក.អ.ក ” ដែលបានអនុម័តរួចមកហើយ ។

ទី ៤ : អនុប្រធាន “ ក.អ.ក ” ត្រូវរាយការណ៏ជាប្រចាំអំពីលទ្ធផលការងារ និង សេចក្តីសំរេចផ្សេង ៗ ដែលខ្លួនបានធ្វើក្នុងក្របខ័ណ្ឌនៃការអនុវត្តន៏សិទ្ធិដូចបានបញ្ជាក់ខាងលើនេះ ថ្វាយសម្តេចក្រុមព្រះ និង ជូន “ ក.អ.ក ” ។

ប្រការ ៤ : “ គជក ” មានរចនាសម្ព័ន្ធដូចតទៅ :

- ផ្នែករដ្ឋបាល ទទួលបន្ទុកក្នុងការទទួលរៀបចំ ថែរក្សាឯកសារ និង ផ្តល់ពត៌មាន

- ផ្នែកកម្មវិធីវិនិយោគ ទទួលបន្ទុករៀបចំគំរោង និង កម្មវិធីវិនិយោគ
- ផ្នែកវិភាគគំរោង ទទួលបន្ទុកវិភាគគំរោងរបស់អ្នកវិនិយោគ ទាំងខាងហិរញ្ញវត្ថុ ទាំងខាងសេដ្ឋកិច្ច
- ផ្នែកនីតិកម្ម ទទួលបន្ទុកលើការងារ ដែលទាក់ទងទៅនឹងប្រព័ន្ធច្បាប់ និង បទបញ្ញត្តិផ្សេង ៗ
- ផ្នែកបរិដ្ឋាន ទទួលបន្ទុកវិភាគពីឥទ្ធិពលនៃគំរោងនីមួយ ៗ ទៅលើបរិដ្ឋាន
- ផ្នែកត្រួតពិនិត្យ ទទួលបន្ទុកកិច្ចការ តាមដាន លើកវិធានការណ៍ ដើម្បីអនុវត្ត និង កំម្រែតម្រង់ការអនុវត្តន៍ សេចក្តីសំរេចរបស់ " ក.អ.ក " និង កិច្ចសន្យាផ្សេង ៗ ។

ប្រការ ៥ : " គជក " ប្រើប្រាស់ត្រារបស់ " ក.អ.ក " ។

ប្រការ ៦ : អនុប្រធាន " ក.អ.ក " អគ្គលេខាធិការ លេខាធិការ នៃ " ក.អ.ក " គណៈកម្មាធិការជាតិវិនិយោគ និង បណ្តាសាមីជន ដែលមានពាក់ព័ន្ធ មានភារកិច្ចអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
ព្រះហស្តលេខា និង ត្រា

នរោត្តម រណឫទ្ធិ

* * * *

## III ការងារបណ្តាក្រសួង
## ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

### ១ - សេចក្តីសំរេច